ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២២១

ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៣

សាលដីកា

លេខ : ១៥៨

ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៦

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឌិត មុន្ទី ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោក វេឿល ធួន ជាចៅក្រម

៣-លោក ស៊ិន ឌឹម ជាចៅក្រម

៤-លោក ឈឹម ស៊ីផល ជាចៅក្រម

៥-លោក សោម សិរីវឌ្ឍ ជាចៅក្រម

៦-លោក គង់ គីរុន ជាចៅក្រម

៧-លោក យស់ សួរឡឿន ជាចៅក្រម

៨-លោក ប៉ែន សាវឿន ជាចៅក្រម

៩-លោក ម៉ុង មុន្នីចរិយា ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី លោកស្រី ទី រាវី

តំណាងមហាអយ្យការ លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ០៣ "ឈ" ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥០ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ប៉ែន សែត ជាតំណាងគណៈកម្មការវត្តប្រជុំវង្ស "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៧០ឆ្នាំ ជាតិខ្មែរ របររកស៊ីអាចារ្យវត្តប្រជុំវង្ស ទីលំនៅសព្វថ្ងៃផ្ទះលេខ១៤៩ ក្រុម៧ ភូមិឫស្សីស្រស់ សង្កាត់និរោធ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។ មានមេធាវីឈ្មោះភុំ បូជាន់ ។

និងចុងចម្លើយឈ្មោះ សោម ចាន់ទី ជាតំណាងប្រជាជន ១៦គ្រួសារ "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៤១ឆ្នាំ ជាតិខ្មែរ របររកស៊ី នៅផ្ទះ ទីលំនៅសព្វថ្ងៃ ភូមិតាងៅ សង្កាត់និរោធ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ សោម សន (ស) ម្តាយឈ្មោះ ព្រំ សារុន (ស) ។

មានមេធាវីឈ្មោះ ស៊ឹម ស៊ីថាន ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារសិទ្ធិគ្រប់គ្រងដីស្រះ

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ ៥២ ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះ សំ ពុធ តំណាងឱ្យគណៈកម្មការវត្តប្រជុំវង្ស ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ០៣"៧" ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ លើចំណុច នៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២២១ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ១៩៩៨ របស់ឈ្មោះ ចាន់ គុណ ប្តឹងទាមទារដីពីប្រជាជនចំនួន ១៤គ្រួសារ ដោយអាងហេតុថាដីនេះជាដីរបស់វត្តដែលប្រជាជន ១៤គ្រួសារបានមករស់នៅ ដែលធ្វើឱ្យប៉ះពាល់ដល់ទ្រព្យគរុភណ្ឌវត្ត ។

បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ១៩៩៨ របស់ឈ្មោះ សោម ចាន់ទី តំណាងឱ្យប្រជាជន ១៤គ្រួសារ ប្តឹងសុំសិទ្ធិគ្រប់គ្រងដីទំនាស់ ។

បានឃើញសាលក្រមរដ្ឋប្បវេណី របៀបលេខ ០១"៧" ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់តុលាការ ក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

-ចាត់របៀបដោយស្រាវជ្រាវរកគំនូរប្លង់ត្រឹមត្រូវ ដែលការិយាល័យភូមិបាលស្រុកមានជ័យ ធ្វើឱ្យអភិបាលស្រុកមានជ័យ និងចាត់បង្កើតគណៈកម្មការចំរុះមួយដោយរួមមាន : ក្រសួងធម្មការ នាយកដ្ឋានសុរិយោដី និងភូមិបាលខ័ណ្ឌមានជ័យ រដ្ឋអំណាចមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ដើម្បីចុះពិនិត្យ និងគូរប្លង់ឱ្យបានត្រឹមត្រូវ កំណត់អំពីព្រំដីវត្តឱ្យបានច្បាស់លាស់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣០"៧" ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការ ក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ១៩៩៨ និងបណ្តឹងតប ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ១៩៩៩ របស់ឈ្មោះ ចាន់ គុណ ជាដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ១៩៩៨ របស់ឈ្មោះ សោម ចាន់ទី តំណាងឱ្យប្រជាជន ១៤គ្រួសារ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែលើកចោលដោយផ្ទុយពីគតិច្បាប់ ។

៣-បង្គាប់ឱ្យប្រជាជនទាំង ១៤គ្រួសារ ដែលរស់នៅក្នុងបរិវេណវត្តប្រជុំវង្ស សង្កាត់ទឹកថ្លា ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ រុះរើផ្ទះដែលស្នាក់នៅចាកចេញពីដីវត្តប្រជុំវង្ស ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលសាលក្រមនេះក្លាយជាស្ថាពរ ។

៤-ប្រគល់ដីទំនាស់ទំហំផ្នែកខាងត្បូង ទទឹង ៦៤ម៉ែត្រ (ហុកសិបបួនម៉ែត្រ) ទំហំផ្នែកខាងជើង ទទឹង ៥៤ម៉ែត្រ (ហាសិបបួនម៉ែត្រ) និងមានព្រំប្រទល់ខាងលិចទល់នឹងដីឈ្មោះ ចាប សុជាន់ ដីឈ្មោះ ធូ គឹមលី និងដី កុង ស្រេង ព្រំប្រទល់ខាងកើតទល់នឹងផ្លូវ ព្រំប្រទល់ខាងត្បូងទល់នឹងដីឈ្មោះ ធូ គឹមលី និងដីឈ្មោះ សូ ប៊ុនណាក ព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ឱ្យទៅគណៈកម្មការវត្តប្រជុំវង្ស ដែលមាន

លោក ឆាន ឌុក ជាតំណាង កាន់កាប់គ្រប់គ្រងជាសម្បត្តិគរុភណ្ឌ ប្រើប្រាស់ក្នុងផ្លូវព្រះពុទ្ធសាសនា តាមច្បាប់តទៅ ។

៥-បង្គាប់ឱ្យប្រជាជនទាំង ១៤គ្រួសារ ដែលមានឈ្មោះ សោម ចាន់ទី ជាតំណាងរួមគ្នា បង់ប្រាក់ប្រដាប់ក្តី និងពន្ធសមាហារតាមច្បាប់ ។

៦-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី មេធាវីគូក្តី សម្រេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ សោម ចាន់ទី ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ១៩៩៩ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបរបស់សាលាឧទ្ធរណ៍លេខ ១៤"ក" ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០០ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ចាត់ភ្នាក់ងារការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល ឱ្យធ្វើកំណត់ហេតុបញ្ជាក់លើគំនូសផែនទី ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ១៩៩៤ និងបញ្ជាក់កន្លែងចុងចម្លើយទាំងអស់គ្នា អ្នកណាខ្លះបាននៅក្នុងដីវត្ត និងបញ្ជាក់បរិវេណវត្ត មានអ្វីជាមូលដ្ឋានថា ទីតាំងទំនាស់ជាដីបរិវេណវត្ត ។

២-ចាត់ឱ្យរដ្ឋអំណាចមូលដ្ឋានធ្វើបញ្ជីស្រង់ឈ្មោះអ្នករស់នៅលើដីបរិវេណវត្ត មានឈ្មោះអ្នកណាខ្លះ ? ម្នាក់ៗនៅលើចំណុចណា ?

៣-ចាត់បញ្ចូលឈ្មោះ អ៊ុក សន, នូ ស, នូ សារឹម អ្នកដែលរស់នៅក្នុងបរិវេណដីវត្ត ដាក់មក ខាងចុងចម្លើយ ។

៤-ធ្វើអង្កេតគ្រប់មធ្យោបាយដែលអាចធ្វើបាន ដោយមានចុះទៅពិនិត្យដល់ទីតាំងទំនាស់ជាដើម ។

បានឃើញសាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍លេខ ៩៥"ក" ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះ សោម ចាន់ទី តំណាងឱ្យប្រជាជន ១៤គ្រួសារ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៣០"ញ" ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជី ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និងអាផ្ទាធរតុលាការ ៥ ០០០រៀល សរុប ១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ មេធាវីដើមចោទ នូ ស. នូ សារឹម. អ៊ុន សន តំណាងមុខឈ្មោះ នួន ផល្លា. ផាន់ សាមុត. ឈឹម ណារិទ្ធ. អ៊ុង ស៊ាន. ភួង សារ៉េត. អ៊ុង នាង. ទឹម ខុម. ឈឹម ណារិន. ស្រី សំបូរ. ស៊ាង មុំ. អ៊ូ សុខ. ផ្លុង មុត. ស៊ាង ស្រី. ងិន ភារម្យ បើកផ្លូវប្ដឹងទាស់ និងប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់របស់ឈ្មោះ ផ្លុង មុត. ខៀវ សន. នួន ផល្លា. ឈឹម ណារិន. អ៊ុង ស៊ាន. ឈឹម ណារិទ្ធ. ភួង សារ៉េត. អ៊ុង នាង. ទឹម ខុម. ស្រី សំបូរ. ស៊ាង មុំ. ស៊ាង ស្រី. ងិន ភារម្យ និងឈ្មោះ ស៊ុក ណម ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០១ ប្ដឹងមិនសុខចិត្តលើសេចក្ដីសំរេច នៃសាលដីកា ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍លេខ ១០ "ក" ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០១ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០១ របស់ឈ្មោះ ផ្លុង មុត. ខៀវ សាន. នួន ផល្លា. ឈឹម ណារិន. អ៊ុង ស៊ាន. ឈឹម ណារិទ្ធ. ភួង សារ៉េត. អ៊ុង នាង. ទឹម ខុម. ស្រី សំបូរ ស៊ាង មុំ. ស៊ាង ស្រី. ងិន ភារម្យ និងឈ្មោះ ស៊ុក ណម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាលេខ ៩៩ "ក" ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈមុខដើមចោទ និងចំពោះមុខចុងចម្លើយឈ្មោះ ផាន់ សាមុត. នួន ផល្លា. ទឹម ខុម. ស៊ាង ស្រី. សុខ ចាន់នី(តំណាង)តំណាងមុខឈ្មោះ ផ្លុង មុត ខៀវ សាន. ឈឹម ណារិន. អ៊ុង ស៊ាន. ឈឹម ណារិទ្ធ. ភួង សារ៉េត. អ៊ុង នាង. ស្រី សំបូរ. ស៊ាង មុំ. ងិន ភារម្យ និង ស៊ុក ណម បើកផ្លូវតវ៉ា ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខរបស់ឈ្មោះ នួន ផល្លា. ផាន់ សាមុត. ឈឹម ណារិទ្ធ. អ៊ុង ស៊ាន. ភួង សារ៉េត. អ៊ុង នាង. ទឹម ខុម. ឈឹម ណារិន. ស្រី សំបូរ. ស៊ាង មុំ. ខៀវ សាន. ផ្លុង មុត. ស៊ាង ស្រី និង ងិន ភារម្យ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០១ ប្ដឹងមិនសុខចិត្តលើសេចក្ដីសំរេច នៃសាលដីកាទាំងមូល ។

បានឃើញសាលដីការបស់តុលាការកំពូល លេខ ១០៦ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០២ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងសាទុក្ខលេខ ១៦២ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០១ របស់លោក នួន ផល្លា. លោក ផាន់ សាមុត. លោក ឈឹម ណារិទ្ធ. លោក អ៊ុង ស៊ាន. លោក ភួង សារ៉េត. លោក អ៊ុង នាង.

អ្នកស្រី ទឹម ខុម. លោក ឈឹម ណារិន. អ្នកស្រី ស្រី សំបូរ. អ្នកស្រី ស៊ាង មុំ. អ្នកស្រី ខៀវ សាន. លោកស្រី ផ្លុង មុត. អ្នកស្រី ស៊ាង ស្រី. អ្នកស្រី ងិន ភារម្យ ទុកជាត្រឹមត្រូវតាមទម្រង់ និងតតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ពេញទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៨៨ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-របអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលម្ចាស់បណ្តឹងសាទុក្ខ បានបង់ទុកនៅតុលាការកំពូល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល

-ហើយ តម្រូវអោយលោក ប៉ែន សែត សងប្រាក់ចំនួន ១៩.០០០រៀល ទៅម្ចាស់បណ្តឹងសាទុក្ខវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០២ ។

បានឃើញសាលដីការបៀបរបស់សាលាឧទ្ធរណ៍លេខ ២៣ "ឈ" ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០២ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបធ្វើការស៊ើបអង្កេតបន្ថែមលើដីទំនាស់នេះអោយបានច្បាស់លាស់ ។ ក្នុងករណីចាំបាច់ក្រុមប្រឹក្សាជំនុំជំរះ និងចុះពិនិត្យដល់ទីកន្លែងដីទំនាស់ ។

២-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងគូក្តី ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ០៣ "ឈ" ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០០៣ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ ៥០ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីការដ្ឋប្បវេណីលេខ ១០៦ ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០២ របស់តុលាការកំពូល ។

២-ចាត់បញ្ចូលឈ្មោះ ស៊ុំ ប៊ិច អាយុ ៧៣ឆ្នាំ ជាតិខ្មែរ ប្តីឈ្មោះ នូ សន (ស្លាប់) និងឈ្មោះ នូ សារឹម ភេទស្រី អាយុ ៣៨ ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិតាងៅ សង្កាត់និរោធ ខ័ណ្ឌមានជ័យ រាជធានី

សុក ណម, ឈឹម ណារិទ្ធ, អ៊ុង សាន, ភួង សារ៉ែត, អ៊ុង នាង, ទឹម ខុម, ឈឹម ណារិន, ស្រី សំបូរ, ស៊ាង ម៉ុំ, ខៀវ សាន, ផ្លុង មុត ( មានឈ្មោះ ងួន ចាន់ធូ ជាតំណាង ), ស៊ាង ស្រី និង ងិន ភារម្យ កាន់កាប់ គ្រប់គ្រង និងប្រើប្រាស់តទៅ ។

៤-ប្រគល់ដីទំនាស់ត្រង់ចំណុច A នៃគំនូសប្លង់បង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ១៩៩៩ របស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ខ័ណ្ឌមានជ័យ ស្ថិតនៅភូមិតាងៅ សង្កាត់និរោធ ខ័ណ្ឌមានជ័យ ឱ្យទៅឈ្មោះ ស៊ុ ប៊ុច និងឈ្មោះ នូ សារឹម កាន់កាប់គ្រប់គ្រង និងប្រើប្រាស់តទៅ ។

៥-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀលដែលចុងចម្លើយបានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ៊ឹងចំនួន ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន ៥.០០០រៀល និងអាជ្ញាធរតុលាការ ៥.០០០រៀល ។ នៅពេលសាលដីកានេះចូលជាស្ថាពរ បង្គាប់ឱ្យដើមចោទសងប្រាក់ចំនួន ១៣.០០០រៀល នេះទៅចុងចម្លើយវិញ និងបង្គាប់អោយដើមចោទបង់ពន្ធសមាមាត្រ ១ភាគរយ លើថ្លៃដីទំនាស់ ។

៦-សាលដីកានេះ ជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០២ ខែមករា ឆ្នាំ២០០៣ ចំពោះមុខមេធាវីតំណាងគូក្តី និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩ ខែមករា ឆ្នាំ២០០៣ ចំពោះមុខគូក្តី កំបាំងមុខមេធាវីតំណាងគូក្តី តែទុកជាចំពោះមុខ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី ២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៣ របស់ ឈ្មោះ សំ ពុធ តំណាងឱ្យគណៈកម្មការវត្តប្រជុំវង្ស ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃសាលដីកា ទាំងមូល ។

បានឃើញសាលដីការបៀបរបស់តុលាការកំពូលលេខ ១៨៧ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៤ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបធ្វើការអង្កេតបន្ថែម ហើយបើក្នុងករណីចាំបាច់ចាត់ក្រុមប្រឹក្សាជំនុំជំរះចុះពិនិត្យសល់ទីតាំងដីទំនាស់ ។

២-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៤ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ ៥២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះ សំ ពុធ តំណាងឱ្យគណៈកម្មការវត្តប្រជុំវង្ស ស្ថិតនៅក្នុងកំណត់ច្បាប់ ។

បានឃើញ សារណារបស់ឈ្មោះ សំ ពុធ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៣ ។

បានឃើញ សារណាតបរបស់ប្រជាជន ១៦គ្រួសារ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០០៤ ។

បានឃើញរបាយការណ៍របស់ ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការ ថា :

-បណ្តឹងសាទុក្ខលើកទី២ របស់ដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបាន ។

សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះ រ៉ែន សែត តំណាងឱ្យគណៈកម្មការវត្តប្រជុំវង្ស (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះឆ្លើយថា :

-ដីនេះជាដីរបស់វត្ត មានប្លង់ត្រឹមត្រូវ ជាដីស្រែរបស់វត្ត ខាងកើតស្ថិតក្នុងរបងវត្ត ខាងលិចស្ថិតនៅក្រៅរបងវត្ត ។ ខ្លួនសុំបដិសេធ ពុំព្រមប្រគល់ឱ្យឈ្មោះ នួន ផល្លា ទេ ព្រោះឈ្មោះនេះចាប់យកមួយកន្លែងហើយ យកមួយកន្លែងទៀត តែក្រៅពីនេះសុខចិត្តប្រគល់ឱ្យ តាមទំហំផ្ទះដែលបានសង់ ។ ហើយដីដែលនៅសល់សុំទុកជាដីរបស់វត្ត ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សោម ចាន់នី តំណាងឱ្យប្រជាជន ១៤ គ្រួសារ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះឆ្លើយថា :

-ដីនេះជាដីលំនៅដ្ឋាន នៅតាំងពីឆ្នាំ១៩៧៩ មក មានប័ណ្ណគ្រួសារត្រឹមត្រូវ ហើយដីដែលនៅសល់ ក្រៅពីសង់ផ្ទះ គឺប្រជាជនចែកគ្នាដាំត្រកួន ដើម្បីដោះស្រាយជីវភាព តែក្រោយពីវត្តប្តឹងគេហាមឃាត់មិនឱ្យដាំ ។

មេធាវីរបស់ដើមចោទ ធ្វើសេចក្តីសន្និដ្ឋានថា :

-កូនក្តីខ្លួនសុខចិត្តប្រគល់ឱ្យចំនួន ១៣គ្រួសារ លើកលែងតែមួយគ្រួសារចេញ គឺមិនប្រគល់ឱ្យទេ ហើយដីដែលនៅសល់ត្រូវទុកជាដីរបស់វត្ត ។

មេធាវីរបស់ចុងចម្លើយ ធ្វើសេចក្តីសន្និដ្ឋានថា :

-ការប្តឹងរបស់ដើមចោទ ពុំមានការអនុញ្ញាតពីចៅអធិការវត្តទេ ។ ដីនេះប្រជាជនបានគ្រប់គ្រងមានប័ណ្ណគ្រួសារតាំងពីឆ្នាំ១៩៧៩ និងបានដាំដំណាំ ។ សុំឱ្យប្រជាជនបានកាន់កាប់ដីនេះ តាមភាពជាក់ស្តែងទាំង១៦គ្រួសារ ។

-ក្រោយពីបានស្តាប់ របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាង មហាអយ្យការ

-ក្រោយពីបានស្តាប់ ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋាន របស់មេធាវីគូភាគី

-ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៣ របស់លោក សំ ពុធ ជាតំណាងឱ្យគណៈកម្មការវត្តប្រជុំវង្ស ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿង

នេះមកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់លាសាជំរះក្តី និងមាត្រា ២២៦ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីបានផងដែរ ។

-យល់ឃើញថា តាមលិខិតបញ្ជាក់នានារបស់ស្ថាប័នពាក់ព័ន្ធ ដូចជាលិខិត ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០១ របស់មន្ទីរធម្មការ និងសាសនារាជធានីភ្នំពេញ. លិខិត ១១៥ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០១ របស់ **ព្រះមេគណរាជធានីភ្នំពេញ** និងលិខិតលេខ ២១០០ របក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ របស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ. ប័ណ្ណស្នាក់នៅ និងលិខិតស្នើសុំ កាន់កាប់ដីរបស់ភាគីចុងចម្លើយរៀង១ខ្លួន គឺជាភស្តុតាងដែលបញ្ជាក់អោយឃើញថាភាគីចុងចម្លើយទាំង១៤គ្រួសារ ពិតជាបានចូលកាន់កាប់ និង គ្រប់គ្រងជាប់ជានិរន្តន៍នូវភាគខ្លះនៃដីទំនាស់ ទាំងក្នុងប្លង់ B តាមទីតាំងដែលកំពុងរស់នៅជាក់ស្តែងតាំងតែពីរវាងឆ្នាំ ១៩៧៩-១៩៨០ មុនពេលវត្តប្រជុំវង្សត្រូវបានបង្កើតឡើងកាលពីឆ្នាំ ១៩៩៤ មកម្ល៉េះ ។

-យល់ឃើញថា ដីនេះមានទីតាំងនៅខាងក្រៅរបងវត្ត ខ័ណ្ឌដាច់ពីបរិវេណវត្ត ដោយរបងវត្ត និងដោយផ្លូវលំ ដែលមានតាំងពីសង្គមចាស់មកម្ល៉េះ ហើយក៏គ្មានសំណៅការ ឬសំណង់អ្វី ដែលជាសម្បត្តិសាសនាដែលអាចសម្គាល់បានថាជាដីដែលធ្លាប់គ្រប់គ្រងដោយវត្តឡើយ ។

-យល់ឃើញថា ការដែលដើមចោទសំអាងលើ គំនូសប្លង់ កំណត់ព្រំប្រទល់វត្តប្រជុំវង្ស ចុះថ្ងៃ ទី ២៥ ខែ តុលា ឆ្នាំ ១៩៩៤ នោះជាការពុំត្រឹមត្រូវទេ ព្រោះប្លង់នេះក្តោបយកទាំងផ្លូវសាធារណៈខាងលិចវត្តផង ម្យ៉ាងទៀតលោកគ្រូចៅអធិការវត្តប្រជុំវង្ស ព្រះនាម កែវ នាង បានបដិសេធហត្ថលេខា និងត្រា របស់ព្រះអង្គមិនឯកភាពអោយដេញប្រជាជនចេញទេ ។

-យល់ឃើញថា ដីទំនាស់មិនមែនជាស្រះរបស់វត្តឡើយ គឺជាត្រពាំង ឬជាអាងស្តុកទឹក ដែលជាដីសាធារណៈរបស់រដ្ឋ ឯស្រះរបស់វត្ត ស្ថិតនៅខាងកើតក្នុងបរិវេណរបងវត្ត ។

-យល់ឃើញថាការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់ដីទំនាស់ក្នុងប្លង់Bទាំងមូលអោយទៅភាគីចុងចម្លើយទាំង ១៤ គ្រួសារនោះ ជាការពុំត្រឹមត្រូវទេ ព្រោះថា តាមកំនត់ហេតុ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការចុះពិនិត្យជាក់ស្តែងរបស់ចៅក្រមប្រឹក្សាតុលាការកំពូល តាមអំណាចសាលដីការបៀបដោយមានការចូលរួម និង ឯកភាពពីតំណាងរបស់គូភាគី បានផ្តិតមេដៃយល់ព្រម លើគំនូសប្លង់បង្ហាញទីតាំងដីទំនាស់ បញ្ជាក់អោយឃើញថា ក្នុងប្លង់ B ចុងចម្លើយទាំង ១៤ គ្រួសារ បានគ្រប់គ្រង តែដីទីតាំងលំនៅដ្ឋានដែលពួកគេកំពុងរស់នៅប៉ុណ្ណោះ ហើយក៏មានភាគដែលនៅទំនេរដែរ ។ ដូចនេះគប្បីទទួលស្គាល់សិទ្ធិគ្រប់គ្រងរបស់ ចុងចម្លើយលើទីតាំងជាក់ស្តែងដែលកំពុងរស់នៅ រីឯដីទំនេរត្រូវទុកជាសម្បត្តិសាធារណៈ ។

-យល់ឃើញថា សាលាឧទ្ធរណ៍មានកំហុសក្នុងនីតិវិធី ដោយទទួលបណ្តឹងរបស់ដើមចោទ ដែលទាមទារដីក្នុងប្លង់ A នៃគំនូសប្លង់បង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់ការិយាល័យ រៀបចំ ដែនដីនគរូបនីយកម្ម និងសំណង់ ភូមិបាល ខ័ណ្ឌមានជ័យ ពីព្រោះចំណុចនេះ ដើមចោទ

មិនបានប្តឹងទាមទារ ពីតុលាការ ថ្នាក់ក្រោមមកនោះទេ ។ ប៉ុន្តែដោយការសម្រេចរបស់សាលាឧទ្ធរណ៍ចំពោះ ប្លង់ A ត្រឹមត្រូវ ហើយនោះគប្បីរក្សាទុកដែល ។

-យល់ឃើញថា សាលដីការជ្ជប្បវេណីលេខ ០៣ "ឈ" ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសខ្លះ ត្រូវខ្លះ ទាំងទម្រង់ និងគតិច្បាប់ ប៉ុន្តែដើម្បីងាយស្រួលក្នុងការសរសេរ គប្បីតុលាការកំពូលបដិសេធទាំងមូល ហើយសម្រេចឡើងវិញជាថ្មី។

ហេតុដូចនេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៥២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៣ របស់ឈ្មោះ សំ ពុធ ជាតំណាងអោយគណៈកម្មការវត្តប្រជុំវង្ស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹង គតិច្បាប់ ។

២-ទុកជាមោឃៈ សាលដីការជ្ជប្បវេណីលេខ០៣ "ឈ" ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-ក.ប្រគល់ដីចំណុច ABCD នៃប្លង់ B តាមគំនូសប្លង់បង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី១៥ ខែ តុលា ឆ្នាំ ២០០៤ របស់ចៅក្រមប្រឹក្សាតុលាការ កំពូលអោយទៅប្រជាជន ១៤ គ្រួសារ និងប្រើប្រាស់ ដោយកំណត់ :

-ចំណុច A ស្ថិតនៅលើព្រំរបងខាងជើង ឆៀងខាងកើតរបស់ឈ្មោះ ឈឹម ណារិទ្ធិ

-ចំណុច B ស្ថិតនៅលើ ចំណុចដែលគិតពីចំណុច A មានប្រវែង ៦៩ ម៉ែត្រ តាមបណ្តោយ ផ្លូវលំ

-ចំណុច C ស្ថិតនៅលើព្រំខាងលិច ដោយទាញចេញពីចំណុច B ដោយបន្ទាត់ BC កាត់កែង នឹងបន្ទាត់ AB

-ចំណុច D នៅលើជ្រុងខាងជើង ឆៀងខាងលិច

ខ-រីឯដីចំណុច CBEF ត្រូវទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ និងហាមឃាត់ការលក់ដូរ និង ផ្ទេរទៅជាកម្មសិទ្ធិរបស់ឯកជន។

គ-ប្រគល់ដីទំនាស់ក្នុងប្លង់ A តាមគំនូសប្លង់បង្ហាញទីតាំងខាងលើអោយទៅឈ្មោះ នូ សន និង នូ សារីម (ស៊ុំ ប៊ិច) គ្រប់គ្រង និងប្រើប្រាស់តទៅ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោកមេធាវី ស៊ាង បូរ៉ាវី បានបង់នៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០ រៀល។

៥-សាលដីកានេះ ជំនុំជំរះសវនាការជាសាធារណៈ នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៦ និងប្រកបជាសាធារណៈនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៦។